Australian Government

Job Services Australia
people • skills • jobs

# ជួយលោកអ្នកដើម្បីចាប់ផ្តើមអាជីវកម្មខ្នាតតូច ៖
# New Enterprise Incentive Scheme

អ្នកស្វែងរកការងារធ្វើដែលមានសិទ្ធិទទួលជំនួយ ហើយមានចំណាប់អារម្មណ៍ក្នុងការចាប់ផ្តើម និងបើកអាជីវកម្មខ្នាតតូច អាចទទួលបានជំនួយតាមរយៈគម្រោងលើកទឹកចិត្តការបង្កើតអាជីវកម្មថ្មី (New Enterprise Incentive Scheme [NEIS] )។

NEIS ផ្តល់នូវការបណ្តុះបណ្តាលហ្វឹកហ្វឺនអាជីវកម្មខ្នាតតូច ដែលមានការទទួលស្គាល់ ការណែនាំអំពី អាជីវកម្ម និងជំបូន្មានសម្រាប់អ្នកស្វែងរកការងារធ្វើដែលមានសិទ្ធិទទួលជំនួយ ក៏ដូចជាជំនួយទ្រទ្រង់ប្រាក់ចំណូលជាបន្តជាប្រចាំ សម្រាប់រយៈពេលរហូតដល់ ៥២សប្តាហ៍។

ស្ថាប័ន NEIS របស់លោកអ្នកនឹងជួយលោកអ្នកក្នុងការសម្រេចចិត្ត ថាតើលោកអ្នកគួរចូលសិក្សា Certificate III ស្តីពីប្រតិបត្តិការអាជីវកម្មខ្នាតតូច (Micro-Business Operation) ឬ Certificate IV ស្តីពីការគ្រប់គ្រងអាជីវកម្មខ្នាតតូច (Small Business Management) ។ ទាំងនេះគឺអាស្រ័យទៅលើប្រភេទអាជីវកម្មខ្នាតតូចដែលលោកអ្នកកំពុងគ្រោងគិតគូរ។ នៅក្នុងអំឡុងពេលបណ្តុះបណ្តាលហ្វឹកហ្វឺន លោកអ្នកក៏ត្រូវបង្កើតផែនការអាជីវកម្មផងដែរ ដែលនឹងត្រូវមានការយល់ព្រមពីស្ថាប័ន NEIS របស់លោកអ្នក។

បើសិនជាផែនការអាជីវកម្មរបស់លោកអ្នកទទួលបានការឯកភាពហើយ លោកអ្នកនឹងទទួលបានជំនួយ NEIS ដែលនឹងមាន ៖

- ប្រាក់ឧបត្ថម្ភ NEIS មានរយៈពេលរហូតដល់ ៥២សប្តាហ៍
- ជំនួយពី NEIS សម្រាប់ជួលទីកន្លែង ដែលមានរយៈពេលរហូតដល់ ២៦សប្តាហ៍ (ប្រសិនបើលោកអ្នកមានសិទ្ធិទទួលជំនួយនេះ)។
- ការណែនាំនិងការជួយទ្រទ្រង់អាជីវកម្មក្នុងអំឡុងពេលប្រកបអាជីវកម្មឆ្នាំដំបូង

កំណត់ចំណាំ៖ អ្នកទទួលប្រាក់សោធនឧបត្ថម្ភជនពិការ (Disability Support Pension) ប្រាក់ជំនួយសម្រាប់អ្នកថែទាំ (Carers Payment) ប្រាក់ជំនួយសម្រាប់ចិញ្ចឹមកូន (Parenting Payment) និងប្រាក់សោធនរបស់ក្រសួងកិច្ចការអតីតយុទ្ធជន (Department of Veterans' Affairs) មួយចំនួនអាចជ្រើសរើសទទួលប្រាក់ជំនួយទាំងនេះដដែល នៅអំឡុងពេលចូលរួមក្នុង NEIS។

## តើអ្នកណាខ្លះអាចចូលរួមបាន?

ដើម្បីចូលរួមក្នុង NEIS លោកអ្នកត្រូវចុះឈ្មោះជាមួយស្ថាប័នផ្តល់សេវាការងារអូស្ត្រាលី (Job Services Australia)។ ស្ថាប័នរបស់លោកអ្នកអាចប្រាប់លោកអ្នកបាន ថាតើលោកអ្នកមានសិទ្ធិចូលរួម ឬយ៉ាងណា។ ទន្ទឹមគ្នានេះ លោកអ្នកក៏ត្រូវតែ ៖

- មានអាយុយ៉ាងតិច ១៨ ឆ្នាំ នៅពេលចាប់ផ្តើមទទួលជំនួយ NEIS។
- អាចចូលរួមក្នុងការបណ្តុះបណ្តាលហ្វឹកហ្វឺនចាំបាច់ និងធ្វើការពេញលេញក្នុងអាជីវកម្ម NEIS ដែលបានស្នើ*
- មិនមែនជាអ្នកក្ស័យធននៅជំពាក់បំណុល។
- មិនធ្លាប់ទទួលបានជំនួយ NEIS សម្រាប់សកម្មភាពអាជីវកម្មស្រដៀងគ្នានឹងអាជីវកម្មស្នើឡើងថ្មី។
- មិនធ្លាប់បានទទួលជំនួយ NEIS ក្នុងរយៈពេល ២ឆ្នាំ មុននេះ

* ឬមានការអនុញ្ញាតឲ្យធ្វើការតិចជាងចំនួនម៉ោងកំណត់ ប្រសិនបើជនណាម្នាក់បានទទួលការវាយតម្លៃថាពុំមានសមត្ថភាពពេញលេញក្នុងការធ្វើការ ឬបានទទួលការកាត់បន្ថយតម្រូវការឲ្យចូលរួមធ្វើការងារ ឬក៏ជាអ្នកស្ម័គ្រចិត្តទទួលសេវាការងារ។

ដូចគ្នានេះដែរ អាជីវកម្ម NEIS របស់លោកអ្នកត្រូវតែ៖

- មិនកំពុងធ្វើអាជីវកម្មអ្វីមួយឡើយនៅពេលបច្ចុប្បន្ននេះ
- មានភាពម្ចាស់ការ សមត្ថភាពក្នុងការទប់ទល់នឹងការពិនិត្យពិច័យពីសាធារណជន និងមានលក្ខខណៈស្របច្បាប់
- មានការវាយតម្លៃដោយស្ថាប័ន NEIS ថាអាចធ្វើអាជីវកម្មរកកម្រៃបាន។
- មិនផ្អែកលើការទិញឬសេងយកនូវអាជីវកម្មដែលមានស្រាប់រួចមកហើយ
- មិនប្រកួតប្រជែងដោយផ្ទាល់ជាមួយអាជីវកម្មដែលមានស្រាប់ លើកលែងតែមានលទ្ធភាពបង្ហាញច្បាស់លាស់ថាមានតម្រូវការផលិតផល ឬសេវាដែលពុំមានគ្រប់គ្រាន់ ឬមានការផ្តល់ផលិតផល ឬសេវាតាមវិធីថ្មី។
- បានបង្កើត មានទីតាំង និងដំណើរការក្នុងប្រទេសអូស្ត្រាលីតែប៉ុណ្ណោះ។
- ស្ថិតក្នុងតំបន់ខ្វះខាតជំនាញ សម្រាប់អ្នកស្វែងរកការងារធ្វើដែលមានជីវភាពទីទ័លជួបការលំបាក។

## ភារកិច្ចរបស់លោកអ្នក

លោកអ្នកចាំបាច់ត្រូវធ្វើអាជីវកម្ម NEIS តាមផែនការអាជីវកម្មរបស់លោកអ្នក ហើយត្រូវធ្វើតាមគ្រប់លក្ខខណ្ឌក្នុងកិច្ចព្រមព្រៀងសម្រាប់អ្នកចូលរួមក្នុង NEIS (NEIS Participant Agreement)។ ប្រសិនបើដោយប្រការណាមួយ លោកអ្នកចង់ផ្លាស់ប្តូរលក្ខណៈអាជីវកម្មរបស់លោកអ្នក (ដូចជាប្តូរទីតាំង ឬម៉ោងធ្វើអាជីវកម្ម) លោកអ្នកត្រូវពិភាក្សាអំពីការផ្លាស់ប្តូរទាំងនេះ ជាមួយស្ថាប័ន NEIS របស់លោកអ្នកជាមុនសិន មុននឹងធ្វើការផ្លាស់ប្តូរ។ ប្រសិនបើលោកអ្នកផ្លាស់ប្តូរការរៀបចំដំណើរការអាជីវកម្មរបស់ខ្លួន ដោយគ្មានការយល់ព្រមនោះ គេអាចផ្អាកប្រាក់ជំនួយ NEIS របស់លោកអ្នក ។

1FS09446JSA/khmer

# សិទ្ធិឯកជនរបស់លោកអ្នក

ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ត្រូវបានការពារដោយ *ច្បាប់ឯកជនឆ្នាំ១៩៨៨ (Privacy Act 1988)* ហើយព័ត៌មានអំពីលោកអ្នក អាចត្រូវបានការពារផងដែរដោយ *ច្បាប់ (រដ្ឋបាល) សន្តិសុខសង្គមឆ្នាំ១៩៩៩ (Social Security [Administration] Act 1999)* (ឧទាហរណ៍ ប្រសិនបើលោកអ្នកទទួលប្រាក់ជំនួយទ្រទ្រង់ប្រាក់ចំណូល)។ ព័ត៌មានរបស់លោកអ្នកអាចផ្តល់ទៅឲ្យស្ថាប័ន NEIS ស្ថាប័ន Job Services Australia  ព្រមទាំងក្រសួងអប់រំការងារ និងទំនាក់ទំនងកន្លែងធ្វើការ [DEEWR] (Department of Education, Employment and Workplace Relations [DEEWR]) ប្រើប្រាស់រួមគ្នាជាមួយ Centrelink និងក្រសួង ក៏ដូចជាទីភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីផ្សេងៗទៀត ដើម្បីផ្តល់លទ្ធភាពឱ្យអង្គការទាំងនោះ ផ្តល់ជូនលោកអ្នកនូវសេវាដ៏សមស្របបំផុតដើម្បីបំពេញតាមតម្រូវការរបស់លោកអ្នក។

ចំពោះព័ត៌មានបន្ថែមអំពីភាពឯកជនរបស់លោកអ្នក សូមសាកសួរស្ថាប័ន NEIS របស់លោកអ្នក ស្ថាប័ន Job Services Australia, DEEWR ឬបើកមើលវ៉ិបសាយថ៍ **privacy.gov. au** ។

# ការធានាផ្តល់ សេវារបស់យើងជូនលោកអ្នក

## ការធានាសេវា

លោកអ្នកនឹងទទួលបានសេវា NEIS ដែលផ្តល់ដោយស្ថាប័នផ្តល់សេវា NEIS របស់លោកអ្នក ក្នុងអំឡុង ពេលធ្វើអាជីវកម្ម ១២ខែដំបូង។ សេវាទាំងនេះនឹងសម្រប់សម្រួលទៅតាមស្ថានភាព និងប្រវត្តិរូបរបស់លោកអ្នក។ ដើម្បីមើលការធានាសេវាទាំងអស់ សូមបើកមើល **deewr.gov.au/jobservicesaustralia**។

## ក្រមសីលធម៌វិជ្ជាជីវៈ

ស្ថាប័ន NEIS ចុះកិច្ចសន្យាក្នុងការផ្តល់សេវា NEIS ដែលមានការឧបត្ថម្ភថវិកាពីរដ្ឋាភិបាលអូស្ត្រាលី ហើយបានព្រមព្រៀង និងប្តេជ្ញាប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈនៃការផ្តល់សេវាការងារ (Employment Services Code of Practice)។ ដើម្បីមើលក្រមសីលធម៌វិជ្ជាជីវៈ សូមបើកមើល **deewr.gov.au/jobservicesaustralia**។

# ចំពោះព័ត៌មានបន្ថែម

**សូមទូរស័ព្ទទៅលេខ 13 17 64 ឬបើកមើលវ៉ិបសាយថ៍ deewr.gov.au/jobservicesaustralia ។**